

# ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការកសាងផែនការអភិវឌ្ឍន៍

*យន្តការគាំទ្រអង្គការសង្គមស៊ីវិល*



បានទទួលមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR)
អនុវត្តដោយអង្គការភ្លែនអន្តរជាតិកម្ពុជាសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន និងដៃគូរបស់ ADB/SPCR ផ្សេងទៀត

ADB

PLAN INTERNATIONAL

## អំពីការប្រែប្រួលអាកាសធាតុ

អាកាសធាតុកំពុងតែមានការប្រែប្រួលនៅទូទាំងសកលលោក។ ការប្រែប្រួលទាំងនេះស្ទើរតែទាំងស្រុងគឺបណ្តាលមកពីសកម្មភាពរបស់មនុស្សព្រោះថានៅពេលដែលយើងប្រើប្រាស់នូវឥន្ធនៈផូស៊ីល ដូចជា ប្រេងធ្យូងថ្ម "ឧស្ម័នផ្ទះកញ្ចក់" គឺបានបំភាយទៅក្នុងបរិយាកាស ដែលធ្វើឲ្យប៉ះពាល់ដល់អាកាសធាតុនៅលើពិភពលោក។ សកម្មភាពដទៃផ្សេងទៀតរបស់មនុស្ស ក៏រួមចំណែកបង្កឲ្យមានការប្រែប្រួលអាកាសធាតុផងដែរ ឧទាហរណ៍៖ ការកាប់បំផ្លាញព្រៃឈើគឺជាបុព្វហេតុមួយដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ ព្រោះថាការកាប់បំផ្លាញព្រៃឈើ គឺបានកាត់បន្ថយលទ្ធភាពភពផែនដីរបស់យើងក្នុងការស្រូបយកកាបូនឌីអុកស៊ីត។

ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ជាច្រើន ដូចដែលយើងធ្លាប់មានបទពិសោធន៍ គឺការកើនឡើងសីតុណ្ហភាពមធ្យម ជាសកលដែលបង្កឲ្យមានការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ភាពញឹកញាប់ និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃព្យុះទីហ្វុង និងផលប៉ះពាល់ធ្ងន់ធ្ងរដទៃទៀតរបស់អាកាសធាតុហើយពិភពលោកទាំងមូលមានការប្រែប្រួលនូវរបបទឹកភ្លៀង ដែលបង្កជាទឹកជំនន់ និងគ្រោះរាំងស្ងួត។ ជាលទ្ធផលដំណាំកសិកម្មទទួលបានទិន្នផលទាប គ្រោះមហន្តរាយប៉ះពាល់ដល់ប្រជាជនកាន់តែច្រើនឡើង និងកាន់តែញឹកញាប់ឡើង ដែលជំរុញឲ្យគ្រួសារ និងសហគមន៍កាន់តែពិបាកក្នុងការចាកចេញពីភាពក្រីក្រ។ ផលប៉ះពាល់ទាំងនេះជាកត្តាគំរាមកំហែងនិងកត្តារាំងដ៏ធំមួយដល់ដំណើរការឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ជាងនេះទៅទៀតការប្រែប្រួលអាកាសធាតុប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋក្រីក្រនិងងាយរងគ្រោះ។ ប្រមាណជា ៧០%នៃគ្រោះមហន្តរាយដែលកើតមានឡើងនាពេលថ្មីៗនេះគឺទាក់ទងនឹងអាកាសធាតុ ហើយទំហំនៃផលប៉ះពាល់នេះគឺទំនងជាអាចមានការរីកដុះដាល ព្រោះថាដំណើរការប្រែប្រួលអាកាសធាតុធ្វើឲ្យកើនឡើងនូវកត្តាដែលមិនអាចទស្សន៍ទាយបាន និងអានុភាពនៃព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុ។

## ការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា

ខណៈពេលដែលគេគិតពីការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតនៅក្នុងពិភពលោក។ដោយសារហេតុផលមួយចំនួនមានដូចខាងក្រោម៖

- វិសមភាព និងភាពក្រីក្ររបស់ប្រជាពលរដ្ឋមានកម្រិតខ្ពស់
- ភាពញឹកញាប់នៃការកើនឡើងនូវគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងគ្រោះមហន្តរាយធ្ងន់ធ្ងរដទៃទៀត
- ប្រជាពលរដ្ឋកម្ពុជាភាគច្រើនពឹងផ្អែកលើការងារកសិកម្ម និងការនេសាទ ដែលជាវិស័យងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុអាស្រ័យហេតុនេះធ្វើឲ្យសន្តិសុខស្បៀង និងជីវភាពរបស់ប្រជាពលរដ្ឋក៏ងាយទទួលរងនូវផលប៉ះពាល់កាន់តែខ្លាំងឡើងៗដែរ។

អាស្រ័យហេតុនេះ ប្រជាពលរដ្ឋកម្ពុជាទាំងបុរស ស្ត្រី កុមារា កុមារី សហគមន៍ និងតំបន់ទាំងមូលចាំបាច់ត្រូវតែពង្រឹងសមត្ថភាពរបស់ពួកគាត់ឲ្យកាន់តែប្រសើរឡើង ដើម្បីទប់ទល់នឹងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុ។ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍ មានតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់សហគមន៍ដែលងាយរងគ្រោះដោយកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ (CCA) និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)។

## ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ គឺជារបៀបដែលប្រជាពលរដ្ឋនិងប្រព័ន្ធទាំងឡាយធ្វើការកែតម្រូវដើម្បីសម្របទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ គម្រោងកម្មវិធីបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជំរុញឲ្យប្រជាពលរដ្ឋមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុដែលអាចឲ្យសហគមន៍មានភាពល្អប្រសើរឡើង ក្នុងការទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់នានា ។ មានភាពខុសគ្នាពីយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលត្រូវស្វែងរកការកាត់បន្ថយនូវមូលហេតុនៃការប្រែប្រួលអាកាសធាតុដោយផ្ទាល់ ឧទាហរណ៍ ការកាត់បន្ថយការប្រើប្រាស់ឥន្ធនៈផូស៊ីល ឬការអភិរក្សព្រៃឈើជាដើម។ តែផ្ទុយទៅវិញការបន្ស៊ាំ នឹងការប្រែប្រួលអាកាសធាតុគឺសំដៅលើការឆ្លើយតបនឹងផលប៉ះពាល់ មិនមែនលើមូលហេតុនៃការប្រែប្រួលអាកាសធាតុនោះទេ។

ការបន្ស៊ាំទៅនឹងប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមានសកម្មភាពផ្សេងៗជាច្រើនហើយវាក៏មិនមែនផ្តោតលើវិស័យតែមួយ ឬក៏មនុស្សមួយក្រុមដែរ តែគម្រោងទាំងឡាយណាដែលជំរុញឲ្យមានភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុត្រូវបានគេគិតថាជាគម្រោងបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។ វិស័យចម្បងៗទាំងនោះ រួមមាន កសិកម្ម ការនេសាទ ការគ្រប់គ្រងធនធានទឹក សុខភាពសាធារណៈ ការអប់រំ ការដឹកជញ្ជូន និងការអភិវឌ្ឍន៍ ទីក្រុង។ល។ លើសពីនេះការងារបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុអាចមានក្នុងវិស័យផ្សេងៗទៀតជាច្រើនផងដែរ ។

ការប្រែប្រួលអាកាសធាតុបង្កផលប៉ះពាល់ដល់ក្រុមមនុស្សផ្សេងៗគ្នាក្នុងរូបភាពផ្សេងៗគ្នា ជាពិសេសគឺជាក្រុមដែលងាយរងគ្រោះរួចទៅហើយ ក្រុមដែលត្រូវបានគេផាត់ចេញពីសង្គម ហើយពួកគេមានធនធានតិចតួចក្នុងការទប់ទល់ជាមួយនឹងការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព។

បទអន្តរាគមន៍ចំពោះការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុអាចប្រព្រឹត្តិទៅគ្រប់កម្រិត ចាប់តាំងពីកម្រិតពិភពលោករហូតដល់កម្រិតសហគមន៍។ ការបន្ស៊ាំនៅកម្រិតសហគមន៍ គឺនឹងត្រូវផ្តល់ឲ្យប្រជាពលរដ្ឋនូវឧបករណ៍ចំណេះដឹង ដើម្បីគ្រប់គ្រងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ជាញឹកញាប់ សហគមន៍តូចៗទាំងនៅទីក្រុងនិងជនបទ ដែលមានធនធានតិចតួចបំផុតអាចអនុវត្តការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានសហគមន៍មានប្រសិទ្ធភាពខ្ពស់ដោយសារតែការកំណត់ឲ្យបានច្បាស់លាស់នូវតម្រូវការ និងការពង្រឹងការចូលរួមរបស់ស្ត្រីនិងក្រុមងាយរងគ្រោះផ្សេងទៀត។ វាក៏ជាការរួមចំណែកក្នុងការ "ការសិក្សាពិសោធន៍"ដើម្បីសាកល្បងគំនិតផ្តួចផ្តើមថ្មី និងការកំណត់នូវការអនុវត្តល្អៗ ដើម្បីពង្រីកគម្រោង ឬ ដកគម្រោងចេញ។



កសិករអនុវត្តការចិញ្ចឹមត្រីតាមគោលការណ៍ធម្មជាតិ

## យន្តការគាំទ្រអង្គការសង្គមស៊ីវិល

ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមគម្រោង "ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការកសាងផែនការអភិវឌ្ឍន៍" មានគោលបំណងផ្តល់ហិរញ្ញប្បទានខ្នាតតូចទៅដល់អង្គការសង្គមស៊ីវិលកម្ពុជា(CSOs) ប្រហែលជា ២០-២៥ គម្រោង ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការដាក់បញ្ចូលនិងការអនុវត្តសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយយកសហគមន៍ជាមូលដ្ឋាន ទៅក្នុងការងារប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។ ជំនួយប្រហែលជា ១.៤00.000 ដុល្លារ នឹងត្រូវបានប្រើប្រាស់ក្នុងការផ្តល់ហិរញ្ញប្បទានទាំងនេះ។ អង្គការដែលទទួលហិរញ្ញប្បទានខ្នាតតូចពីកម្មវិធីនេះ នឹងទទួលបាននូវវគ្គបណ្តុះបណ្តាលនិងការណែនាំ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់ពួកគេនៅក្នុងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

កម្មវិធីនេះរួមចំណែកបំពេញកិច្ចខិតខំប្រឹងប្រែងកាន់តែទូលំទូលាយដែលបាននឹងកំពុងអនុវត្តដោយព្រះរាជាណាចក្រកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ដើម្បីលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងការបំពេញតាមគោលដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៣ ដល់ ២០១៨ ផែនការយុទ្ធសាស្ត្រ ការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤ ដល់ ២០២៣ និងគោលបំណងនៃគោលនយោបាយផ្សេងៗទៀត។ យន្តការគាំទ្រអង្គការសង្គមស៊ីវិល នេះបានបង្កើតឡើងដើម្បីធានាថាអង្គការសង្គមស៊ីវិលត្រៀមរួចជាស្រេច ហើយអាចចូលរួមយ៉ាងពេញលេញក្នុងយុទ្ធសាស្ត្រ និងដំណើរការបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ ។

អង្គការសង្គមស៊ីវិលទាំងឡាយដែលអនុវត្តការងារទាក់ទងនឹងគម្រោងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយនៅប្រទេសកម្ពុជាអាចដាក់សំណើសុំហិរញ្ញប្បទានខ្នាតតូចបាន។

យន្តការគាំទ្រអង្គការសង្គមស៊ីវិល នេះនឹងផ្តល់ហិរញ្ញប្បទានខ្នាតតូចដល់អង្គការសង្គមស៊ីវិលសម្រាប់ការអនុវត្តសកម្មភាពនៅសហគមន៍ នូវកញ្ចប់ថវិការហូតទៅដល់ ១00,000ដុល្លាអាមេរិក ដែលនឹងត្រូវអនុវត្តគម្រោងរយៈពេល ១៨ខែចាប់ពីដើមឆ្នាំ២០១៦ នេះតទៅ។ អង្គការដែលមានបំណងចូលរួម អាចស្នើគម្រោងយកមកអនុវត្តក្នុងវិស័យផ្សេងៗ តែត្រូវលើកឡើងពីភាពងាយរងគ្រោះ និងភាពធន់នឹងហានិភ័យនៃប្រែប្រួលអាកាសធាតុ។

យន្តការគាំទ្រអង្គការសង្គមស៊ីវិល ស្វាគមន៍ដល់ស្ថាប័នដាក់ពាក្យស្នើសុំហិរញ្ញប្បទានខ្នាតតូច ដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋងាយរងគ្រោះមានក្រុមស្ត្រី កុមារ ជនពិការ ជនជាតិដើមភាគតិច និងក្រុមដែលងាយរងគ្រោះដទៃទៀត។

## ដំណើរការជ្រើសរើសស្ថាប័នដៃគូ

- ដាក់សំណើ ចំណាប់អារម្មណ៍ (ត្រឹម ខែកញ្ញា) — ២០១៥
- ជ្រើសរើស អង្គការសង្គមស៊ីវិលទាំង៣៥ — ២០១៥
- វគ្គបណ្តុះបណ្តាល #១ ការបញ្ជ្រាបគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ — ២០១៥
- អង្គការសង្គមស៊ីវិលទាំង៣៥ រៀបចំសំណើសុំថវិកា — ២០១៥
- ពិនិត្យមើលសំណើសុំថវិកា និងជ្រើសរើសអង្គការសង្គមស៊ីវិលចំនួន ២០ — ២០១៥
- កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ក្រសួងបរិស្ថាន និង ADB អនុម័ត ហិរញ្ញប្បទាន និងជ្រើសរើសស្ថាប័នដៃគូ — ២០១៦
- វគ្គបណ្តុះបណ្តាល # ២ ការបញ្ជ្រាបគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ — ២០១៦
- ការអនុវត្តគម្រោងដោយមានការកែតម្រូវ និងការបណ្តុះបណ្តាលបន្តបន្ទាប់ និងការត្រួតពិនិត្យ — ២០១៦-២០១៧
- ការបញ្ចប់គម្រោងដែលអនុវត្តដោយអង្គការសង្គមស៊ីវិល — ២០១៧



កសិករអនុវត្តសួនដំណាំធម្មជាតិ

## ឧទាហរណ៍មួយចំនួនរួមមាន៖

### វិស័យកសិកម្ម ព្រៃឈើ និងនេសាទ

- ការអភិរក្សផ្ដោតលើសហគមន៍ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវពូជដំណាំក្នុងស្រុក ជីវចំរុះនិងព្រៃឈើដែលធន់នឹងគ្រោះទឹកជំនន់ កម្ដៅ និងគ្រោះរាំងស្ងួត
- ការអនុវត្តប្រព័ន្ធវារីវប្បកម្ម កសិកម្ម និងព្រៃឈើដែលមានភាពឆ្លាតវៃធន់នឹងអាកាសធាតុ (ឧទាហរណ៍៖ ការគ្រប់គ្រងសត្វល្អិត សារធាតុចិញ្ចឹម និងទឹក ការថ្លឹងថ្លែងនៅក្នុងលំនាំដំណាំដាំដុះ ការដាំដើមឈើឡើងវិញ និងការបណ្ដុះដើមឈើដោយផ្ដោតលើសហគមន៍ យន្តការចែករំលែកហានិភ័យនៅថ្នាក់សហគមន៍ជាដើម) ដើម្បីបង្កើនសន្តិសុខស្បៀងក្នុងស្រុក និងភាពធន់របស់សហគមន៍

### វិស័យធនធានទឹក

- បច្ចេកទេសគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅសហគមន៍មូលដ្ឋាន (ឧទាហរណ៍៖ ការរៀបចំអាងត្រងទឹក ភ្លៀង ការរៀបចំប្រព័ន្ធធារាសាស្ត្របែងចែកការប្រើប្រាស់ទឹក ការស្ដារប្រព័ន្ធធារាសាស្ត្រខ្នាតតូចដោយប្រើប្រភពថាមពលកកើតឡើងវិញ ស្រះខ្នាតតូច ទំនប់ទឹក បច្ចេកទេសជីវវិស្វកម្មនៅតាមបណ្ដោយច្រាំងទន្លេ ដើម្បីកាត់បន្ថយសំណឹកដី ប្រព័ន្ធប្រកាសអាសន្នជាមុនជាដើម)
- កិច្ចខិតខំប្រឹងប្រែងនៅតាមសហគមន៍ ដើម្បីទប់ស្កាត់ការហូរចូលទឹកប្រៃនៅតំបន់ឆ្នេរនិងការសម្របខ្លួនទៅនឹងគ្រោះទឹកជំនន់នៅតាមតំបន់ឆ្នេរ (ការអភិរក្សដើមកោងកាង ការស្ដារទំនប់ទឹកតូច និងច្រាំងថ្ម)

### វិស័យអភិវឌ្ឍន៍ទីក្រុង

- ការអនុវត្តន៍យុទ្ធសាស្ត្រអនាម័យ និងទឹកស្អាតនៅតាមសហគមន៍ ដើម្បីឱ្យប្រសើរឡើងនូវសុខមាលភាព ប្រជាពលរដ្ឋនៅក្នុងតំបន់ទីក្រុង
- ប្រព័ន្ធប្រកាសឲ្យដឹងមុននៅសហគមន៍មូលដ្ឋាន និងវិធានការរៀបចំផ្ទះសម្បែងដែលមានសុវត្ថិភាពក្នុងការទប់ ទល់នឹងគ្រោះទឹកជំនន់។ល។

### វិស័យដឹកជញ្ជូន

- កិច្ចខិតខំប្រឹងប្រែងនៅសហគមន៍មូលដ្ឋាន ដើម្បីបង្កើនភាពធន់នៃផ្លូវជនបទតាមរយៈជីវៈវិស្វកម្ម និងវិធីសាស្ត្រច្នៃប្រឌិតថ្មីៗ ដើម្បីរក្សាដីជម្រាលកុំឲ្យបាក់ដី
- វិធានការការពារផ្លូវថ្នល់ និងស្ពាននៅសហគមន៍មូលដ្ឋាន (ឧទាហរណ៍ប្រព័ន្ធលូធ្វើឱ្យប្រសើរឡើង)

### វិស័យសុខភាព

- វិធានការថ្នាក់សហគមន៍ ដែលកំណត់យ៉ាងជាក់លាក់ពីហានិភ័យសុខភាពពាក់ព័ន្ធនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត
- ប្រព័ន្ធនៅតាមសហគមន៍ ដើម្បីកាត់បន្ថយឧប្បត្តិហេតុនៃការកើតឡើងនូវជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាមជាដើម

### វិស័យថាមពល

- ប្រព័ន្ធថាមពលកកើតឡើងវិញដែលរៀបចំនៅសហគមន៍មូលដ្ឋានដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពបន្សាំរបស់សហគមន៍ និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់ជនបទ (ឧទាហរណ៍ ប្រព័ន្ធជីវឧស្ម័ន, វារីអគ្គិសនីខ្នាតតូច, ការស្រោចស្រពដំណាំដោយប្រើថាមពលព្រះអាទិត្យ, ចង្ក្រានប្រើអុសធ្យូងដែលត្រូវបានធ្វើឱ្យប្រសើរឡើង)
- វិធានការថ្នាក់សហគមន៍ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធថាមពលពីផលប៉ះពាល់នៃទឹកជំនន់

### វិស័យទេសចរណ៍

- វិធានការនៅតាមសហគមន៍ ដើម្បីការពារកន្លែងទេសចរណ៍ពីគ្រោះទឹកជំនន់
- វិធានការធ្វើឲ្យប្រសើរឡើងនូវភាពធន់នឹងអាកាសធាតុរបស់សហគមន៍ដែលរកប្រាក់ចំណូលបានទាបដោយពឹងផ្អែកលើវិស័យទេសចរណ៍ នៅក្នុងតំបន់ជនបទ (ឧទាហរណ៍៖ ការពង្រឹងទេសចរណ៍ធម្មជាតិ)

### ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង

- វិធីសាស្ត្រដែលមានប្រសិទ្ធិភាពក្នុងការប្រាស្រ័យទាក់ទងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ទៅដល់សហគមន៍ (ឧទាហរណ៍ ការសំដែងតាមផ្លូវ វិធីសាស្ត្រប្រាស្រ័យទាក់ទង ការអប់រំ និងព័ត៌មានផ្សេងៗទៀត)

### គោលនយោបាយ និងការរៀបចំផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

- ប្រព័ន្ធរៀបចំផែនការដោយផ្ដោតលើសហគមន៍ប្រកបដោយភាពច្នៃប្រឌិត ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ (ឧទាហរណ៍ ប្រពន្ធ័បម្រុងស្បៀងទុក មូលនិធិសង្គ្រោះបន្ទាន់ និងគំហែទាំថវិកាបម្រុង វិធីសាស្ត្រផ្សេងៗទៀត ដែលរួមបញ្ចូលស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងបន្សាំ ពង្រីកវិសាលភាពនៃកម្មវិធីសិក្សា ដើម្បីរួមបញ្ចូលវិធានការសម្រាប់ការបន្សាំ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅសហគមន៍)


កសិកម្មដែលមានលក្ខណៈសម្របទៅនឹងការប្រែប្រួលអាកាសធាតុ